អត្ថបទបកប្រែពីភាសាអង់គ្លេស
អត្ថបទដើម៖
http://eeas.europa.eu/statements-eeas/2015/150715_05_en.htm

# សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ នៅលើច្បាប់ស្តីពី សមាគម និងអង្គការ មិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា

"នៅថ្ងៃទី ១៣ ខែ កក្កដា ច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាលត្រូវបានអនុម័តតាមរយៈសភាក្នុងប្រទេសកម្ពុជា។ ច្បាប់នេះប៉ះលើបញ្ហារសើបជាច្រើនដែលទាមទារឱ្យមានការពិគ្រោះយោបល់ឲ្យបានស៊ីជម្រៅជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់។ គួរឱ្យសោកស្តាយ បញ្ហាព្រួយបារម្ភសំខាន់ៗមួយចំនួន មិនត្រូវបានយកមកពិចារណារអោយបានគ្រប់គ្រាន់ឡើយ ។ ច្បាប់នេះ មានសក្តានុពលភាពយ៉ាងធំធេងក្នុងការដាក់កំហិតដល់សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល។

នៅក្នុងប្រទេសណាក៏ដោយ សង្គមស៊ីវិលដែលមានភាពរស់រវើក គឺជាលក្ខខណ្ឌជាមុន ក្នុងការធ្វើអោយសម្រេចបាននូវសក្តានុពលសង្គម សេដ្ឋកិច្ច និងនយោបាយពេញលេញមួយ។ សមាគម និង អង្គការមិនមែនរដ្ឋាភិបាល ទាំងក្នុងស្រុកនិងអន្តរជាតិ បានរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការកសាងសង្គមកម្ពុជា។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងសហភាពអឺរ៉ុបនិងកម្ពុជា ពឹងផ្អែកក្នុងកំរិតដ៏ធំមួយលើអង្គការក្រៅរដ្ឋាភិបាល។

ការគោរពដោយពេញលេញចំពោះបញ្ញត្តិរដ្ឋធម្មនុញ្ញ ស្តីពីពហុភាព និង សេរីភាពនៃសមាគម និង សេរីភាពនៃការបញ្ចេញមតិ ត្រូវតែបានលើកតម្កើង"។

****

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


Catherine Ray +32 498 96 99 21 - +32 2 296 99 21 - Catherine.Ray@ec.europa.eu - @CatherineEUspox

Maja Kocijancic +32 498 984 425 - +32 2 298 65 70 - Maja.Kocijancic@ec.europa.eu - @MajaEUspox

Eamonn Prendergast +32 460 75 32 93 - Eamonn.Prendergast@ec.europa.eu